# Living the Lotus 6

## *Buddhism in Everyday Life*

2026
VOL. 249








**Rissho Kosei-kai of Los Angeles**

**Living the Lotus**
**Vol. 249 (June 2026)**

Senior Editor: Takashi Maeda
Editor: Sachi Mikawa
Copy Editor: Penn Setharin

*Living the Lotus* is published monthly
By Rissho Kosei-kai International,
Fumon Media Center, 2-7-1 Wada,
Suginami-ku, Tokyo 166-8537, Japan.
TEL: +81-3-5341-1124
FAX: +81-3-5341-1224
Email: living.the.lotus.rk-international@kosei-kai.or.jp

រីហ្សូកូសេកៃគឺជាអង្គការចលនាពុទ្ធសាសនាសកលមួយដែលមានពុទ្ធបរិស័ទ ជាច្រើនមានជំនឿលើគម្ពីរព្រះសូត្រផ្កាឈូកសដែលជាព្រះសូត្ររបស់ព្រះពុទ្ធសាសនាមួយដ៏សំខាន់។ ពុទ្ធបរិស័ទទាំងនោះ បានខិតខំអនុវត្តការបង្រៀន របស់ព្រះបរមគ្រូនៃយើងទៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃដូចជា នៅកន្លែងការ ងារឬនៅក្នុងក្រុមគ្រួសាររបស់ពួកគាត់ជាដើម។ជាពិសេសគឺខំប្រឹងអនុវត្តធ្វើយ៉ាងណាអោយពិភពលោកទទួលបានសុខសន្តិភាព។

អង្គការរីហ្សូកូសេកៃ ត្រូវបានបង្កើតឡើងនៅឆ្នាំ 1983 ដោយ ស្ថាបនិក Nikkyo Niwano (1906-1999) និង, សហស្ថាបនាយិកា Myoko Naganuma (1889-1957) បច្ចុប្បន្នក្រោមការណែនាំពីលោកប្រធាន Nichiko Niwano សមាជិក រីហ្សូកូ សេកៃទាំងអស់ក្នុងនាមជាពុទ្ធបរិស័ទបានកំពុងប្រឹងប្រែងយ៉ាងសកម្មក្នុងការចែករំលែកព្រះធម៌និងចូលរួមសកម្មភាពសន្តិភាពទាំងក្នុងនិងក្រៅប្រទេសក្នុងកិច្ចសហការជាមួយមនុស្សគ្រប់មជ្ឈដ្ឋាន។

The title of this newsletter, *Living the Lotus—Buddhism in Everyday Life*, conveys our hope of striving to practice the teachings of the Lotus Sutra in daily life in an imperfect world to enrich and make our lives more worthwhile, like beautiful lotus flowers blooming in a muddy pond. This newsletter aims to help people around the world apply Buddhism more easily in their daily lives.

President's Messsage

# សេចក្តីទុក្ខសោកក៏ជាមិត្តនៃជីវិតដែរ

ដោយព្រះគ្រូនីវ៉ាណូ នីជីកុ
ព្រះប្រធានរីស្ហូកូសេកៃ



## សេចក្តីទុក្ខសោកគឺជាអ្វីដែលយើងបង្កើតឡើងដោយខ្លួនយើង

ខ្ញុំព្រះករុណាអាត្មាភាពបានសាកសួរអ្នកទាំងអស់គ្នាជាញឹកញយនូវសំណួរថា "នៅពេលដែលឃើញកែវមួយដែលមានទឹកតែពាក់កណ្តាលតើអ្នកយល់ឃើញនិងមានអា រម្មណ៍បែបណា?"

អ្នកនិពន្ធកូបាយ៉ាស៊ីសេកាំង (S e i k a n K o b a y a s h i ) បាននិយាយថា៖អារម្មណ៍និងការយល់ឃើញរបស់មនុស្សទៅលើបាតុភូតមួយមានបីយ៉ាង។ ទី១សម្តែងសេចក្តីមិនពេញចិត្តមិនសប្បាយចិត្ត "ចុំ!ទឹកមានតែកន្លះកែវហ្នឹង!" ទី២មានអារម្មណ៍រីករាយសប្បាយចិត្តដោយគិតថា"រីករាយណាស់!ទឹកមានដល់ទៅកន្លះកែវ" និងទី៣មានអារម្មណ៍ថាដឹងគុណដោយគិតថា "មានគេទុកទឹកកន្លះកែវឱ្យខ្ញុំដែរទេតើ ពិតជាគួរឱ្យដឹងគុណណាស់"។ ទោះយ៉ាងណាក៏ដោយ អារម្មណ៍ឬការយល់ឃើញនីមួយៗនិងរបៀ បមើលទៅលើអ្វីមួយ គឺយើងខ្លួនយើងជាអ្នកកំណត់អត្ថន័យនោះទៅលើការពិតដែលគ្មានអ្វីក្រៅពី "ទឹកកន្លះកែវ"តែប៉ុណ្ណោះ ។ មិនថាយើងមានអារម្មណ៍មិនពេញចិត្ត ឬទទួលយកវាដោយក្តីរីករាយ ឬដោយអំណរគុណនោះទេ អារម្មណ៍ទាំងអស់នោះគឺជាបញ្ហានៃចិត្តរបស់"អាត្មាអញ"ជាខ្លួនយើងម្នាក់ៗផ្ទាល់។

ចំពោះយើងទាំងឡាយដែលជាគ្រហស្ថខ្ញុំព្រះករុណាអាត្មាភាពជឿថាព្រះធម៌ឬការបង្រៀនប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធត្រូវតែជាពាក្យដែលងាយយល់ហើយអាចអនុវត្តបាននៅក្នុងជីវិតប្រចាំថ្ងៃរបស់យើងតាមដែលអាចធ្វើទៅបាននោះជាការសំខាន់ណាស់។ សំណេររបស់លោក កូបាយ៉ាស៊ីដែលផ្អែកទៅលើព្រះធម៌ឬការបង្រៀនប្រៀនប្រដៅរបស់ព្រះពុទ្ធដែលមានចារនៅក្នុង"គម្ពីរបេះដូងនៃបញ្ញា (H e a r t o f Wi s d o m S u t r a -般若心経) " បង្រៀនថា "រូបរាងគឺទទេសូន្យ" ពោលគឺថា បាតុភូតទាំងអស់ទាំងអ្វីដែលនាំឱ្យរីករាយ និងអ្វីដែលនាំឱ្យឈឺចាប់គឺយើងជាអ្នកកំណត់អត្ថន័យរបស់វាតាមអំពើចិត្តរបស់យើងទាំងអស់ ហើយយើងក៏រីករាយឬឈឺចាប់ទៅ ។ ជាពិសេសបាតុភូតដែលជាមូលហេតុនៃសេចក្តីទុក្ខព្រួយនិងសេចក្តីបារម្ភដែលជារឿយៗជាគ្រាប់ពូជនៃទុក្ខវេទនារបស់យើងគឺកើតឡើងដោយសារតែការគិតដោយគំនិតបែបប្រធានវិស័យរបស់ខ្លួនយើង ដោយភាពលំអៀង ដោយបុរេវិនិច្ឆ័យ ដោយការសន្មតផ្ទាល់ខ្លួនដោយបំណងប៉ងប្រាថ្នា ដោយការសង្ស័យនិងការជាប់ជំពាក់របស់ខ្លួនយើងផ្ទាល់។ខ្ញុំព្រះករុណាអាត្មាភាពជឿថារឿងឧទាហរណ៍នៃ"ទឹកកន្លះកែវ"មុននេះបង្ហាញពីវិធីគិតរបស់ព្រះពុទ្ធសាសនាដែលចាក់ឫសគល់ទៅក្នុងជីវិតប្រចាំថ្ងៃរបស់យើងដោយណែនាំថា "ប្រសិនបើអ្នកប្តូរទស្សនៈរបស់អ្នកនិងរបៀបដែលអ្នកយល់ឃើញទៅលើអ្វីមួយអ្នកនឹងអាចរស់នៅបានកាន់តែងាយស្រួល"។

## ទុក្ខវេទនាក៏ជាពេលវេលាមួយប៉ប្រិចដ៏សំខាន់ក្នុងជីវិតដែរ

"គេតែងតែគិតថាកើត ចាស់ ឈឺ ស្លាប់ជា ទុក្ខទាំងបួន ក៏ប៉ុន្តែសម្រាប់រូបខ្ញុំវាមិនមែនជាទុក្ខទាំងបួនទេ គឺជាសេចក្តីរីករាយទាំងបួន"។ នេះគឺជាពាក្យរបស់សាស្ត្រាចារ្យបណ្ឌិតហៀវ៉ាសាវ៉ា កូ (K o H i r a s a w a )អតីតសាកលវិទ្យាធិការនៃសាកលវិទ្យាល័យក្យូតូ។ គឺលោកចង់និយាយថាជីវិតប្រសិនបើអ្នកប្តូរទស្សនៈរបស់អ្នក វាគឺជាភាគបន្តៗឬជាស៊េរីនៃសេចក្តីរីករាយនិងជាសេចក្តីសប្បាយជាបន្តបន្ទាប់។កវីសាកាមូរ៉ាស៊ីនមីញ(S h i n mi n S a k a mu r a )បានសរសេរកំណាព្យមួយពាក់ព័ន្ធនឹងជំងឺដែលជាទូទៅមនុស្សទាំងឡាយតែងតែចាត់ទុកថាជាការឈឺចាប់។កំណាព្យនោះផ្ទុយទៅវិញបានបង្ហាញពីអារម្មណ៍ដឹងគុណដ៏ទន់ភ្លន់ដូចតទៅនេះ "ជំងឺ / បានបើក / ពិភពលោកមួយផ្សេងទៀត / សម្រាប់ឱ្យផ្កាប៉ែស / រីក"។ អ្នកនិពន្ធប្រលោមលោកស៊ីម៉ូមូរ៉ាខូជីន (K o j i n S h i mo mu r a ) បាននិយាយថា "ពិភពលោកដែលខ្ញុំចង់រស់នៅគឺជាពិភពលោកមួយដែលទុក្ខវេទនាមិនទៅជាមូលហេតុនៃភាពអស់សង្ឃឹមប៉ុន្តែផ្ទុយទៅវិញជាជ្រលួញចាក់ជំរុញឱ្យមានភាពក្លាហាន"។ពាក់ព័ន្ធនឹងការបង្រៀនអំពី "ភាពទទេស្ងុន្យ" ដែលបានបង្ហាញជាឧទាហរណ៍ដោយ"រឿងទឹកកន្លះកែវ"លោកកូបាយ៉ាស៊ី បានមានប្រសាសន៍ថា "ប្រហែលជាព្រះពុទ្ធលោកចង់បង្ហាញដល់យើងថា 'នោះគឺជាការហ្វឹកហ្វឺនដើម្បីស្វែងរកសេចក្តីរីករាយ និងសេចក្តីសប្បាយនៅក្នុងបាតុភូតតែមួយ'ហើយមើលទៅ។

ដូចដែលបានរៀបរាប់នៅក្នុងសៀវភៅដែលមានចំណងជើងថា «មាគ៌ានៃការមើលទៅសកលលោកថាជាសម្ព័ន្ធមិត្ត» (K ōe n s h a ) សូម្បីតែបាតុភូតដែលយើងយល់ឃើញថាជាការឈឺចាប់ក៏យើងអាចមើលឃើញនិងបកស្រាយតាមវិធីផ្សេងទៀតបាន។កត្តានេះបន្តផ្សាប់ទៅនឹងភាពក្លាហានក្នុងការរស់នៅនិងរបៀបរស់នៅថ្មីមួយទៀត។ ប្រសិនបើយើងមើលទៅបាតភូតទាំងឡាយពីទស្សនៈតែមួយជ្រុងថាជាការឈឺចាប់និងទុក្ខលំបាក យើងនឹងនៅតែជាប់គាំងនៅក្នុង«ទុក្ខវេទ នា» នោះហើយខកខានឱកាសដ៏មានតម្លៃសម្រាប់ការរីកចម្រើន។

ទោះជាយ៉ាងណាក៏ដោយ នេះមិនមានន័យថាត្រូវបង្ខំខ្លួនឯងឱ្យទទួលយកព្រឹត្តិការណ៍ដ៏ឈឺចាប់ដោយគំនិតវិជ្ជមាននោះទេ។ វាមានន័យថាចូរមើលទៅអ្វីមួយដោយទស្សនៈពីច្រើនជ្រុងជ្រោយ។ បន្ទាប់មកទោះជាទុក្ខវេទនាដ៏ធំប៉ុនណាក៏ដោយបើអ្នកយកគោលការណ៍អនិច្ចំ, អ្វីៗសុទ្ធតែមិនទៀងនិងសច្ចធម៌ព្រមទាំងនិស្ស័យមកគិតផ្គួបរួមជាមួយ អ្នកនឹងឃើញថាអ្វីៗសុទ្ធតែជាជំនួបដែលចាំបាច់ត្រូវតែមានចៀសមិនផុតក្នុងជីវិតហើយលើសពីនេះទៅទៀតវាហាក់ដូចជាកុមារតូចដែលនឹងលូតលាស់ធំធាត់ទៅជាមនុស្សពេញវ័យដែលជាការបន្តផ្សាប់ទៅនឹងអនាគតកាលប្រកបដោយការច្នៃប្រឌិត ។

នៅក្នុងប្រលោមលោកមួយមានប្រយោគមួយចែងថា"រឿងល្អនិងអាក្រក់ទាំងអស់បានបង្កើតអ្នកជានរណានៅថ្ងៃនេះ។ ប្រសិនបើមិនមានរឿងអាក្រក់ណាមួយទេ អ្នកនឹងមិនក្លាយជាអ្នកឥឡូវនេះទេ។ ហើយប្រសិនបើមិនមានរឿងល្អណាមួយទេ អ្នកក៏នឹងមិនក្លាយជាអ្នកនៅថ្ងៃនេះដែរ"។

ទុក្ខវេទនា និងភាពសោកសង្រេងគឺជាពេលវេលាមួយប៉ប្រិចដ៏សំខាន់នៅក្នុងជីវិតរបស់យើង និងជាបទពិសោធន៍ដ៏មានតម្លៃនៃជីវិត។ ទ្រឹស្តីរូបវិទ្យាវិទូសាជី ហារឹអូ (H a r u o S a j i ) បាននិយាយថា "ប្រសិនបើការប្រមូលផ្តុំគរត្រួតនៃអតីតកាលបង្កើតបានជា'បច្ចុប្ប ន្នកាល' នោះការរចនា 'បច្ចុប្បន្នកាលពីឥឡូវ' ដោយសម្លឹងមើលទៅអនាគតខាងមុខដ៏វែងឆ្ងាយអាចប្តូរទាំងអនាគតនិងអតីតកាលបាន។"ក្នុងន័យនេះដែរការរស់នៅក្នុង "បច្ចុប្បន្នកាល" ដោយយកសេចក្តីរីករាយឬក៏ទុក្ខព្រួយដែលបានប្រមូលផ្តុំគត្រួតពីអតីតកាលមកធ្វើជាដៃគូពេញមួយជីវិតហើយរស់ក្នុងបច្ចុប្បន្នកាលដើម្បីខ្លួនយើងនាពេលអនាគត,ដើម្បីមនុស្សពេញវ័យនាពេលអនាគតនិងអនាគតនៃភពផែនដីទាំងមូលជាការសំខាន់ចាំបាច់ណាស់។ "កាសែតកូសេ"លេខខែមិថុនាឆ្នាំ២០២៦

”កាសែតកូសេ"លេខខែមិថុនាឆ្នាំ២០២៦






# A Global Buddhist Movement




## Information about local Dharma centers

facebook

X

We welcome comments on our newsletter Living the Lotus: [living.the.lotus.rk-international@kosei-kai.or.jp](mailto:living.the.lotus.rk-international@kosei-kai.or.jp)